# អវត្តមានជំនឿពុទ្ធសាសនាក្នុងសង្គមខ្មែរ
## ករណីសិក្សា
## «សម័យកម្ពុជាប្រជាធិបតេយ្យ»

ដោយ បណ្ឌិត **ឈុន សុខា**
ប្រធានផ្នែកអក្សរសាស្ត្រនិងអក្សរសិល្ប៍
នៃវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជា

## មូលន័យសង្ខេប

តាំងពីបុរាណកាលរៀងមក យើងឃើញថា ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជាបានរួមចំណែកយ៉ាងសំខាន់ក្នុងការធ្វើឱ្យប្រទេសមានភាពថ្កុំថ្កើងរុងរឿងនិងកិត្យានុភាពដ៏បវរ។ ប្រជាជនខ្មែរតែងឱ្យតម្លៃព្រះពុទ្ធសាសនានិងបានថែរក្សា លើកតម្កើងពុទ្ធសាសនាជាអត្តសញ្ញាណជាតិខ្មែរ ជាវប្បធម៌ សីលធម៌ ប្រពៃណីទំនៀមទម្លាប់ដ៏ល្អរបស់ជាតិ ព្រមទាំងបានចាត់ទុកថា ពុទ្ធសាសនាបានបង្ហាញផ្លូវរស់នៅដ៏សុខសាន្តដល់ខេមរជនគ្រប់រូបឱ្យដើរឆ្ពោះទៅកាន់សុខសន្តិភាព វិបុលភាព និងសុភមង្គលថែមទៀតផង។

ក្រោយព្រឹត្តិការណ៍រដ្ឋប្រហារថ្ងៃទី១៨ខែមីនា ឆ្នាំ១៩៧០ ប្រទេសកម្ពុជាបានធ្លាក់ក្នុងភ្លើងសង្គ្រាមរវាងខ្មែរក្រហមនិងរបបសាធារណរដ្ឋខ្មែរ។ នៅតាមតំបន់ដែលកាន់កាប់ដោយក្រុមខ្មែរក្រហម យើងឃើញថា វិស័យពុទ្ធសាសនាត្រូវបានរឹងបន្តឹងបន្តិចម្ដងៗ។ រហូតដល់ចលនាតស៊ូនេះបានទទួលជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ វត្តអារាមនៃពុទ្ធសាសនាត្រូវបានបិទទាំងស្រុង ព្រះសង្ឃត្រូវបានផ្សឹកទាំងអស់នៅទូទាំងប្រទេស។

តើនៅពេលអង្គការបំបាត់ចោលនូវជំនឿព្រះពុទ្ធសាសនា វាមានរឿងអ្វីកើតឡើងខ្លះក្នុងសង្គម?

ការបំបាត់ពុទ្ធសាសនា មានន័យថា បំបាត់ធម៌អហិង្សា បំបាត់ការសន្ដោសប្រណី បំបាត់ការអធ្យាស្រ័យ បំបាត់មនុស្សធម៌ ធ្វើឱ្យសង្គមគ្មានគុណធម៌ គ្មានច្បាប់ទម្លាប់ គ្មានការចែករំលែកសុខទុក្ខគ្នាទៅវិញទៅមក។ ជាក់ស្ដែងនៅក្នុងសង្គមនៃរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនរស់ដោយគ្មានសិទ្ធិសេរីភាព រស់នៅដោយភ័យខ្លាច រស់នៅក្រោមអំពើព្រៃផ្សៃយ៉ាងវេទនាជាទីបំផុត។ ការបំបាត់ពុទ្ធសាសនា មានន័យថា បំបាត់វត្តអារាម កាលណាគ្មានវត្តអារាមគឺគ្មានសេចក្ដីសប្បាយរីករាយ។ ការបំបាត់វត្តអារាម មានន័យថា បំបាត់អត្តសញ្ញាណជាតិ បំបាត់វប្បធម៌ អក្សរសាស្ត្រ សាលារៀន ប្រវត្តិសាស្ត្រ ក្បួនគម្ពីរផ្សេងៗជាដើម។ ការរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនពុំមានសិទ្ធិធ្វើបុណ្យតាមប្រពៃណីជាតិទេ បុណ្យដែលសំខាន់ជាងគេនៃកម្ពុជាប្រជាធិបតេយ្យគឺ *ថ្ងៃជ័យជម្នះ១៧ មេសា ១៩៧៥* ដែលអង្គការបានកំណត់យកជាថ្ងៃបុណ្យចូលឆ្នាំថែមទៀតផង។ ការបំបាត់វត្តអារាម មានន័យថា បំបាត់សីលធម៌ចាស់ទុំ ទំនៀមទម្លាប់ប្រពៃណី ព្រោះព្រះសង្ឃជាអ្នកប្រៀនប្រដៅសីលធម៌និងជាអ្នកអប់រំ បង្ហាញផ្លូវនៃជីវិតរស់នៅក្នុងសង្គមដល់ពុទ្ធបរិស័ទ។ ការបំបាត់វត្តអារាមមានន័យថា បំបាត់សាមគ្គីភាពក្នុងសង្គម បំបាត់ទំនាក់

ទំនងសង្គម។ យើងឃើញថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនរស់នៅក្រោមគោលជំហរដែលកំណត់ដោយអង្គការថា *ឯករាជ្យ-ម្ចាស់ការ ក្បាលអ្នកណា សក់អ្នកហ្នឹង ខ្លួនទីពឹងខ្លួន ជាដើម។*

ដូចនេះ អវត្តមាននៃនឿពុទ្ធសាសនាក្នុងរបបកម្ពុជាប្រជាធិបតេយ្យពិតជាបានធ្វើឱ្យសង្គមនាពេលនោះកើតមានបញ្ហាច្រើន ពិសេសការធ្វើឱ្យប្រជាជនរស់នៅក្នុងសភាពភ័យខ្លាចជាប់ជានិច្ច។ អង្គការបានប្រកាន់នូវមនោគមវិជ្ជាបដិវត្តន៍ឆ្វេងនិយមជ្រុល បានធ្វើឱ្យកុមារ យុវជន ក៏ដូចជាជនបដិវត្តន៍មួយចំនួនមានចរិតដាច់ខាត មិនអាចសម្រុះសម្រួលបាន គឺបាត់បង់សីលធម៌ សុជីវធម៌ គុណធម៌ ការសន្តោស ការអធ្យាស្រ័យ ក្នុងសង្គមយើងឃើញមានតែការយកជាតិសាសន៍ឯងធ្វើជាសត្រូវ ដោយចោទប្រកាន់ថាជាខ្មាំង ប្រឆាំងបដិវត្តន៍ និងការកាប់សម្លាប់ជាតិសាសន៍ឯងដោយមិនញញើត។

## សេចក្ដីផ្ដើម

ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាបានបញ្ជាក់ថា ក្នុងអតីតកាលប្រទេសកម្ពុជាមានទឹកដីធំទូលាយ។ ប្រជាជនដែលរស់នៅលើទឹកដីនេះមានប្រវត្តិសាស្ត្រច្បាស់លាស់ មានអរិយធម៌ខ្ពង់ខ្ពស់ ដែលអរិយធម៌នោះបានជះឥទ្ធិពលទៅលើប្រទេសជិតខាងថែមទៀតផង។ អរិយធម៌របស់ខ្មែរតាំងពីដើមរហូតមកដល់បច្ចុប្បន្នមានទំនាក់ទំនងយ៉ាងទៅនឹងសាសនាធំពីរដែលមានប្រភពពីប្រទេសឥណ្ឌា។ ទោះជាប្រជាជនខ្មែរបានទទួលយកជំនឿព្រហ្មញ្ញសាសនានិងពុទ្ធសាសនាក៏ដោយ ក៏ខ្មែរមិនបោះបង់ចោលជំនឿដើមរបស់ខ្លួនទាំងស្រុងទេ។ ទាំងជំនឿថ្មី ទាំងជំនឿខ្មែរដើមត្រូវប្រជាជនសំយោគចូលគ្នាបង្កើតបានជាជំនឿខ្មែរទ្រទ្រង់នូវព្រលឹងជាតិមួយដ៏រឹងមាំ។

ចាប់តាំងពីគ្រិស្តសតវត្សរ៍ទី១៤មក ប្រជាជនកម្ពុជាបានប្រកាន់យកជំនឿពុទ្ធសាសនាថេរវាទជាផ្លូវការនិងក្នុងស្មារតីមួយជាទីពឹងប្រចាំជីវិតរបស់ខ្លួនថែមទៀតផង។ ចំណែកឯសាសនាព្រាហ្មណ៍ដែលធ្លាប់មានឥទ្ធិពលមកលើសតិអារម្មណ៍ប្រជាជនខ្មែរដែរនោះ មិនត្រូវបានប្រជាជនយកជាទីពឹងទៀតទេ។ ហេតុនេះបានជាជំនឿសាសនាព្រាហ្មណ៍ត្រូវជ្រកតាមទំនៀមទម្លាប់ខ្មែរខ្លះ តាមសិល្បៈខ្លះ ជាដើម។ ចាប់ពីការទទួលយកជំនឿពុទ្ធសាសនាថេរវាទតែមួយមក មូលដ្ឋាននៃវប្បធម៌ខ្មែរមួយផ្នែកធំគឺ ព្រះពុទ្ធសាសនា ដែលត្រូវបានប្រជាជនចាត់ទុកជាព្រលឹង ជាអត្តសញ្ញាណរបស់ខ្លួន និងបានធ្វើឱ្យប្រជាជនចេះពិចារណាក្នុងការជឿលើកម្មផល ជឿលើបុណ្យបាប ដឹងគុណដឹងទោស មានហេតុផល ដូចហេតុផលនៃវិទ្យាសាស្ត្រដែរ។

តាំងពីបុរាណកាលរៀងមក ព្រះពុទ្ធសាសនាបានដើតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកធ្វើឱ្យមានភាពថ្កុំថ្កើងរុងរឿងនិងកិត្យានុភាពនៃមាតុភូមិអង្គរដ៏បវរនៃយើង។ ប្រជាជនខ្មែរតែងឱ្យតម្លៃព្រះពុទ្ធសាសនា និងបានថែរក្សា លើកតម្កើង ជាអត្តសញ្ញាណជាតិខ្មែរ ជាវប្បធម៌ សីលធម៌ ប្រពៃណី ទំនៀមទម្លាប់ខ្មែរដ៏ល្អបវររបស់ជាតិ ព្រមទាំងបានចាត់ទុកទស្សនៈនៃពុទ្ធសាសនាបានបង្ហាញផ្លូវរស់នៅដ៏សុខសាន្តដល់ខេមរជនគ្រប់រូបឱ្យដើរឆ្ពោះទៅកាន់សុខសន្តិភាព វិបុលភាព និងសុភមង្គល ដោយចៀសវាងអំពើហិង្សា អកុសលកម្ម បាបកម្មផ្សេងៗទៀតផង។

ការលើកយកប្រធានបទ ***អវត្តមានជំនឿពុទ្ធសាសនាក្នុងសង្គមខ្មែរ សិក្សាករណី សម័យកម្ពុជាប្រជាធិបតេយ្យ*** មកសិក្សាក្នុងពេលនេះ ចង់បង្ហាញឱ្យឃើញថា *នៅពេលអវត្តមានជំនឿពុទ្ធសាសនាក្នុងសង្គមតើសង្គមខ្មែរបានទទួលនូវផលប៉ះពាល់អ្វីខ្លះ?* ការលើកយកប្រធានបទនេះមកសិក្សាគឺ យើងសិក្សាតែក្នុងបរិបទនៃក្នុងដំណាក់កាលនៃការតស៊ូពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ និងដំណាក់កាលក្រោយថ្ងៃជ័យជម្នះ ១៧ មេសា ១៩៧៥ដល់ថ្ងៃ៧ មករា ១៩៧៩តែប៉ុណ្ណោះ។

## ១- ទិដ្ឋភាពទូទៅនៃរបបកម្ពុជាប្រជាធិបតេយ្យ

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សម្ដេចព្រះនរោត្តម សីហនុ ត្រូវលោកសេនាប្រមុខ លន់ នល់ និងមន្ត្រីជំនិតរបស់លោកបានរៀបចំឱ្យរដ្ឋសភាជាតិបោះឆ្នោតទម្លាក់ព្រះអង្គចេញពីតំណែងជាប្រមុខរដ្ឋ។ ព្រឹត្តិការណ៍នេះបានធ្វើឱ្យប្រទេសកម្ពុជាធ្លាក់ក្នុងភ្លើងសង្គ្រាមរវាងក្រុមចលនាតស៊ូខ្មែរក្រហមនិងរបបសាធារណរដ្ឋខ្មែរអស់រយៈពេល៥ឆ្នាំ១ខែ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានទទួលជ័យជម្នះលើរបបសាធារណរដ្ឋខ្មែររបស់លោកសេនាប្រមុខ លន់ នល់ ទាំងស្រុង។

ក្រោយពីទទួលបានជ័យជម្នះ បក្សកុម្មុយនីស្តកម្ពុជាបានបង្កើតរបបកម្ពុជាប្រជាធិបតេយ្យនៅឆ្នាំ១៩៧៦។ ទោះជាយ៉ាងណាក៏ដោយ វត្តមានរបស់អ្នកដឹកនាំបក្សត្រូវបានរក្សាជាសម្ងាត់ ដោយពុំមានអ្នកណាម្នាក់បានស្គាល់ឡើយ។ ក្នុងដំណាក់កាលនោះគេឮតែពាក្យ*អង្គការ* ប៉ុណ្ណោះដែលត្រូវបានហៅចំពោះថ្នាក់ដឹកនាំ។ រហូតដល់ឆ្នាំ១៩៧៧ ទើប ប៉ុល ពត បានប្រកាសជាចំហថា គាត់ជាមគ្គុទេសក៍នៃបក្សកុម្មុយនីស្តកម្ពុជា។

បន្ទាប់ពីទទួលជ័យជម្នះភ្លាម អង្គការបានបង្ខំប្រជាជនឱ្យចេញពីទីក្រុងទៅរស់នៅតាមតំបន់ជនបទដើម្បីធ្វើស្រែចម្ការ។ ក្នុងរបបនេះ អង្គការបានលុបបំបាត់ចោលនូវរូបិយវត្ថុ ទីផ្សារ ការសិក្សាអប់រំ កម្មសិទ្ធិឯកជន ការគោរពជំនឿសាសនាផ្សេងៗ និងប្រពៃណីវប្បធម៌ខ្មែរតាំងពីបុរាណកាលមក។ ប្រជាជនគ្រប់រូបត្រូវបានដកហូតអស់នូវសិទ្ធិជាមូលដ្ឋានរបស់ខ្លួន។ ប្រជាជនទាំងអស់មិនត្រូវបានអនុញ្ញាតឱ្យដើរចេញក្រៅសហករណ៍របស់ខ្លួនទេ។ នៅក្នុងគម្រោងផែនការបួនឆ្នាំរបស់បក្សកុម្មុយនីស្តកម្ពុជា អង្គការបានដាក់ទិសឱ្យប្រជាជនកម្ពុជាទូទាំងប្រទេសចូលរួមបង្កបង្កើនផលឱ្យបានតាមការកំណត់របស់បក្ស។ ប្រជាជនត្រូវធ្វើការជាទម្ងន់ ដោយគ្មានអាហារបរិភោគគ្រប់គ្រាន់ ជាហេតុបង្កឱ្យមានជំងឺស្លាប់ជាបន្តបន្ទាប់។ ជាងនេះទៅទៀត ប្រជាជនក៏ត្រូវបានសម្លាប់ដោយការចោទប្រកាន់ថាជាខ្មាំងរបស់អង្គការយ៉ាងអយុត្តិធម៌ ថែមទៀតផង។ រហូតមកដល់ចុងឆ្នាំ១៩៧៧ ការប៉ះទង្គិចជាមួយប្រទេសវៀតណាមបានផ្ទុះឡើង ប្រជាជនរាប់ម៉ឺននាក់ត្រូវអង្គការបញ្ជូនទៅសមរភូមិ ហើយត្រូវស្លាប់រាប់ពាន់នាក់។ នៅខែធ្នូ ឆ្នាំ១៩៧៨ កងកម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានបង្កើតឡើង និងតស៊ូដើម្បីរំដោះប្រជាជនឱ្យរួចផុតពីទុក្ខសោកនិងក្តីមរណៈនៃរបបប្រល័យពូជសាសន៍នេះ។ រហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានយកជ័យជម្នះលើរបបឃោរឃៅព្រៃផ្សៃនេះ រំដោះប្រជាជនពីការកាប់សម្លាប់និងធ្វើឱ្យអ្វីៗរស់រានមានជីវិតឡើងវិញ។

ក្បាលម៉ាស៊ីនដឹកនាំខ្មែរនៃរបបកម្ពុជាប្រជាធិបតេយ្យដែលនៅសេសសល់ បានរត់គៀសខ្លួនទៅកាន់ជាយដែនខ្មែរ-ថៃ ហើយបានរៀបចំបង្កើតកងកម្លាំងតស៊ូរបស់ខ្លួនទប់ទល់នឹងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដោយមានជំនួយគាំទ្រពីប្រទេសចិននិងថៃ។ ក្នុងគ្រានោះដែរមហាសន្និបាតអង្គការសហប្រជាជាតិបានបោះឆ្នោតផ្តល់អាសនៈកម្ពុជានៅអង្គការសហប្រជាជាតិឱ្យទៅក្រុមអ្នកតស៊ូ ដែលគេយល់ថាប្រឆាំងនឹងកុម្មុយនីស្ត តែក្នុងនោះមានក្រុមខ្មែរក្រហមផងដែរ។ ការចរចាខ្មែរចតុភាគីដែលច្បាំងគ្នាអស់រយៈពេលច្រើនឆ្នាំបានអូសបន្លាយតាំងពីឆ្នាំ១៩៨៧ រហូតដល់ថ្ងៃទី២៣ខែតុលាឆ្នាំ១៩៩១ទើបមានកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីសរវាងខ្មែរទាំងបួនភាគីដែលមានជម្លោះនឹងគ្នា បានចុះហត្ថលេខាយល់ព្រម

បង្កើតរដ្ឋាភិបាលបណ្ដោះអាសន្នមួយសម្រាប់ប្រទេសកម្ពុជា និងនៅឆ្នាំ១៩៩៣ទើបមានការបោះឆ្នោតជាសកលមួយ ក្រោមការរៀបចំនិងត្រួតពិនិត្យដោយអង្គការសហប្រជាជាតិ។ ពេលនោះភាគីកម្ពុជាប្រជាធិបតេយ្យបានធ្វើពហិការមិនព្រមចូលរួមបោះឆ្នោតនេះទេ។ ភាគីកម្ពុជាប្រជាធិបតេយ្យបានទៅតស៊ូនៅក្នុងព្រៃនិងបន្តធ្វើសង្គ្រាមឈ្លបជាមួយរដ្ឋាភិបាលបន្តទៀត។ នៅឆ្នាំ១៩៩៤រាជរដ្ឋាភិបាលបានបញ្ចប់កិច្ចចរចាជាមួយខ្មែរក្រហម និងបានអនុម័តច្បាប់មួយដាក់ពួកនេះឱ្យនៅក្រៅច្បាប់ជាពួកឧទ្ទាមជាផ្លូវការ។

នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៩៧ ប៉ុល ពត ត្រូវឃាត់ខ្លួនដោយអតីតសមមិត្តជាអ្នកនៅបន្ទាប់ពីគាត់។ នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨ ប៉ុល ពត បានទទួលមរណភាព ចលនាតស៊ូខ្មែរក្រហមដែលដឹកនាំដោយ ខៀវ សំផន បានក្ដោបក្ដាប់អំណាចឡើងវិញ។ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ខៀវ សំផន និង នួន ជា បានសុំចុះចូលធ្វើសមាហរណកម្មរស់ក្នុងសង្គមជាតិវិញក្នុងឋានៈជាប្រជាពលរដ្ឋសាមញ្ញ។ ចលនាតស៊ូចុងក្រោយរបស់ខ្មែរក្រហមបានបន្តនិរន្តរភាពរបស់ខ្លួនរហូតដល់ឆ្នាំ១៩៩៩ គឺនៅពេលមេដឹកនាំខ្មែរក្រហមទាំងអស់ចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ខ្លះត្រូវចាប់ខ្លួន និងខ្លះទទួលមរណភាព។

## ២- ទិដ្ឋភាពជំនឿពុទ្ធសាសនាក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ

### ២.១- ទិដ្ឋភាពទូទៅនៃជំនឿពុទ្ធសាសនាក្នុងសង្គមខ្មែរ

ជំនឿសាសនាធំពីរដែលមានប្រភពពីប្រទេសឥណ្ឌាគឺសាសនាព្រាហ្មណ៍ សាសនាព្រះពុទ្ធ ត្រូវបានប្រជាជនខ្មែរថែរក្សា គោរពលាយឡំទៅនឹងជំនឿដើមរបស់ខ្លួនតាំងពីសម័យបុរាណមកម្ល៉េះ។ ប្រជាជនខ្មែរបានរក្សាអរិយធម៌នេះ និងចាត់ទុកជាប្រពៃណីដ៏ប្រពៃរបស់ខ្លួនរហូតមកដល់បច្ចុប្បន្ន។

ប៉ុន្តែនៅសម័យបន្តបន្ទាប់ ប្រជាជនខ្មែរបានប្រកាន់យកតែជំនឿសាសនាព្រះពុទ្ធមួយដោយប្រតិបត្តិខ្ជាប់ខ្ជួន ដែលសាសនានេះបានចូលមកប្រទេសកម្ពុជាតាំងពុទ្ធសតវត្សរ៍ទី៣មុនគ្រិស្តរាជមកម្ល៉េះ[១]។ ចាប់តាំងពីសតវត្សរ៍ទី១៤រហូតមកដល់បច្ចុប្បន្ន ពុទ្ធសាសនាថេរវាទបានប្រតិស្ឋាន ចាក់ឫសជាប់ស៊ប់ឥតប្រែប្រួលនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា[២]។ ប្រជាជនកម្ពុជាបានគោរពប្រតិបត្តិសាសនានេះដោយឥតរវាត។ ទាំងក្នុងសម័យបុរាណក៏ដូចជាសម័យក្រោយៗមកទៀត ពុទ្ធសាសនាបានពង្រឹងខ្លួននិងរីកចម្រើនយ៉ាងរឹងមាំក្នុងសង្គមកម្ពុជា។ តាមការសិក្សាស្រាវជ្រាវ យើងឃើញថា ចាប់តាំងពីសម័យនគរភ្នំ សម័យចេនឡា សម័យអង្គរ ពុទ្ធសាសនាបានដើរតួយ៉ាងសំខាន់ក្នុងវិស័យវប្បធម៌ អក្សរសាស្ត្រ ការអប់រំសីលធម៌ ក៏ដូចជាវិស័យផ្សេងៗទៀតមានការគ្រប់គ្រងសង្គមជាដើម។ រហូតមកដល់សម័យដែលប្រទេសកម្ពុជាបានចុះអាប់ឱននៃដំណាក់កាលរបបអាណាព្យាបាលបារាំង បារាំងបានប៉ុនប៉ងនិងលុបបំបាត់អក្សរសាស្ត្រខ្មែរ ពេលនោះវត្តអារាមនៃពុទ្ធសាសនា ដែលមានព្រះសង្ឃជាតួអង្គដ៏សំខាន់បានដើរតួយ៉ាងសកម្មក្នុងការអភិរក្សវប្បធម៌ អក្សរសាស្ត្រ ប្រពៃណី ទំនៀម ទម្លាប់ជាតិឱ្យគង់វង្សរហូតមកដល់សព្វថ្ងៃ។

---

[១] សូមមើល :*ពុទ្ធសាសនា ២៥០០* ភ្នំពេញ, ការផ្សាយឡើងវិញរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យបោះពុម្ពលើកទី៣ ឆ្នាំ២០០១ ទំព័រ៣៦-៣៩។

[២] -ដ- ទំព័រ១០៨។

តាមរយៈដំណោះស្រាយបញ្ហាដូចបានលើកឡើងទៅតាមសម័យកាលនីមួយៗ ធ្វើឱ្យយើងដឹងច្បាស់ថា វត្តអារាមជាជង្រុកវប្បធម៌ ជាមជ្ឈមណ្ឌលផ្សព្វផ្សាយពុទ្ធិ និងថែរក្សាសម្បត្តិវប្បធម៌ជាតិ តាំងពីអតីតកាលដ៏យូរលង់មកហើយ។

ក្រោយពីទទួលបានឯករាជ្យពីបារាំងនៅឆ្នាំ១៩៥៣ រដ្ឋាភិបាលនៃរបបសង្គមរាស្ត្រនិយមបានយកចិត្តទុកដាក់ខាងវិស័យពុទ្ធសាសនានេះ ដោយធ្វើឱ្យមានភាពជិតស្និទរវាងរដ្ឋាភិបាលនិងវត្តអារាម។ ក្នុងស្មារតីនេះ យើងអាចនិយាយបានថា ជាការជិតជាមជាប់ឥទ្ធិពលពីព្រះមហាក្សត្រមុនៗ ពិសេសព្រះបាទជ័យវរ្ម័នទី៧ ដែលព្រះអង្គបានរៀបចំពិធីពុទ្ធរាជឡើងដើម្បីការដឹកនាំសង្គមរបស់ព្រះអង្គ។ ក្នុងសម័យសង្គមរាស្ត្រនិយម យើងសង្កេតឃើញថា ស្ទើរតែគ្រប់វត្តអារាម សាលារៀនត្រូវបានសាងសង់ឡើងសម្រាប់កុមារបានសិក្សារៀនសូត្រទាំងអក្សរសាស្ត្រ ទាំងសីលធម៌ ដែលមានព្រះសង្ឃជាគ្រូផងដែរ។ ក្នុងសម័យសង្គមរាស្ត្រនិយមវត្តអាមមានចំនួន ៣ ៣៦៩វត្ត និងព្រះសង្ឃមានចំនួន ៦៥ ០៦២អង្គ[៣]។

ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជាចាប់តាំងពីពេលបដិសន្ធិមកមិនដែលសាបសូន្យទេ គ្រាន់តែមានការផ្លាស់ចុះឡើងទៅតាមតម្រូវការសង្គមតែប៉ុណ្ណោះ។ ប៉ុន្តែជាអកុសល ក្នុងកំលុងពេលប្រទេសជួបវិបត្តិសង្គ្រាមស៊ីវិលនាឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ ព្រឹត្តិការណ៍នេះបានធ្វើឱ្យមានការរាំងស្ទះដល់ការគោរពប្រតិបត្តិជំនឿពុទ្ធសាសនា។ ធ្ងន់ធ្ងរជាងនេះទៅទៀត ក្រោយពីក្រុមចលនាតស៊ូខ្មែរក្រហមបានទទួលជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរនាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពុទ្ធសាសនាមិនត្រូវបានឃើញប្រជាជនគោរពប្រតិបត្តិទៀតឡើយក្នុងរយៈពេល៣ឆ្នាំ ៨ខែ និង២០ថ្ងៃ។ ក្រោយពីរបបនេះត្រូវបានផ្តួលរំលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ពុទ្ធសាសនាក៏ត្រូវបានរស់រានមានជីវិតរហូតមកដល់បច្ចុប្បន្ននេះ និងបន្តរីកចម្រើនទៅអនាគត។ មកដល់បច្ចុប្បន្ន វត្តអាមនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានចំនួន ៤ ៥១៤វត្ត និងព្រះសង្ឃមានចំនួន ៥៦ ៨២០អង្គ គិតក្នុងឆ្នាំ២០១៧។

តាមការសិក្សាដោយសង្ខេប យើងឃើញថា ព្រះពុទ្ធសាសនាបានដើរតួយ៉ាងសំខាន់ក្នុងសង្គមខ្មែរ ដោយបានរួមចំណែកធ្វើឱ្យសង្គមជាតិមានភាពចុំច្មើងរុងរឿងនិងមានកិត្យានុភាព ពិសេសការការបង្ហាញផ្លូវឱ្យប្រជាជនរស់នៅដ៏សុខសាន្តនិងដើរឆ្ពោះទៅកាន់សុខសន្តិភាពជានិច្ច។

## ២.២- ជំនឿពុទ្ធសាសនាក្នុងដំណាក់កាលរណសិរ្សតស៊ូពីឆ្នាំ១៩៧០-១៩៧៥

ក្រោយព្រឹត្តិការណ៍រដ្ឋប្រហារនាថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ប្រទេសកម្ពុជាធ្លាក់ចូលក្នុងភ្លើងសង្គ្រាមអស់រយៈពេល៥ឆ្នាំ ១ខែ។ ចលនាតស៊ូខ្មែរក្រហមកាលពីមុនគ្រាន់តែជាចលនាតស៊ូដ៏តូចមួយ ក៏ចាប់ផ្តើមមានកម្លាំងឡើង។ ក្នុងពេលនោះសម្តេចព្រះនរោត្តម សីហនុ បានបង្កើតរណសិរ្សមួយឈ្មោះថា ***រណសិរ្សរួបរួមជាតិកម្ពុជា*** ដើម្បីប្រយុទ្ធតតាំងជាមួយនឹងរបបសាធារណរដ្ឋខ្មែរ។ តាមរយៈរណសិរ្សនេះ ព្រះ អង្គបានអំពាវនាវឱ្យអ្នកដែលគាំទ្រព្រះអង្គនៅក្នុងប្រទេសងើបឡើងបះបោរទៀតផង[៤]។

ក្នុងដំណាក់កាលនៃការតស៊ូរបស់ខ្មែរក្រហមជាមួយរបបសាធារណរដ្ឋខ្មែររបស់ លោក លន់ នល់

---

[៣] ហែម ឡាច : ***លទ្ធិពុទ្ធនិយមក្នុងផ្នត់គំនិតខ្មែរបច្ចុប្បន្ន*** សារណាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកទស្សនវិជ្ជា ឆ្នាំ២០០៤ ទំព័រ១៣០។

[៤] វ៉ាន់ឌី កាអុន : *ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ភាគ២*, ប៉ារីស, រោងពុម្ព [?] បោះពុម្ពលើកទី២, ឆ្នាំ២០០៨ ទំព័រ២៨។

អង្គការបានអប់រំយុវជនឱ្យក្លាយជាជនបដិវត្តន៍ និងទៅជាជនកុម្មុយនីស្តតាមកម្រិតតឹងរឹងខ្លាំងឡើងៗជាលំដាប់។ អង្គការបានយកគោលការណ៍នៃការតស៊ូក្នុងក្របខណ្ឌរណសិរ្សមកបង្ហាត់បង្រៀន អប់រំ ក្នុងបរិបទបដិវត្តន៍ប្រជាជាតិ ដោយអង្គការពន្យល់ប្រជាជនថា យើងធ្វើបដិវត្តន៍នេះគឺដើម្បីរំដោះប្រជាជាតិពីនឹមចក្រពត្តិអាម៉េរិកាំង[៥]។ការអប់រំនយោបាយ អង្គការបានលើកយកទ្រឹស្តីបដិវត្តន៍ប្រជាជាតិ-ប្រជាធិបតេយ្យ មកបង្ហាញតាមរយៈការបំផុសនៃការតស៊ូវណ្ណៈ កំហឹងវណ្ណៈ ដោយគេបានវាយប្រហារដល់ពួកសក្តិភូមិ ពួកនាយទុនកុំប្រាដ័រ។

ដើម្បីឈ្នះសង្គ្រាម ពួកខ្មែរក្រហមបានប្រើប្រាស់គ្រប់យុទ្ធវិធីក្នុងការទាក់ទាញ ប្រមូលកម្លាំងប្រជាជនគ្រប់ស្រទាប់ជាន់ថ្នាក់ ទាំងព្រះសង្ឃ បញ្ញវន្ត ប្រជាជន យុវជន យុវនារី ឱ្យគាំទ្រចលនាតស៊ូរបស់ខ្លួន។ ខាងវិស័យសាសនា ទោះបីអង្គការមិនពេញចិត្ត តែគេមិនទាន់ហ៊ានប៉ះពាល់ខ្លាំងក្លាទេ។ ក្នុងដំណាក់កាលតស៊ូពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ នៅតំបន់រំដោះមួយចំនួនអង្គការនៅអនុញ្ញាតឱ្យយុវជនចូលបួសក្នុងសំណាក់ពុទ្ធសាសនាបាន តែត្រូវមានសុំច្បាប់ពីប្រធានរណសិរ្សឃុំ[៦]។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក្នុងភាពជាសង្ឃក្នុងដំណាក់កាលនោះ ហាក់ដូចជាមិនមានលក្ខណៈណាមួយស្រួលខាងផ្លូវចិត្ត ដើម្បីរៀនធម៌នោះទេ។ ប្រធានរណសិរ្សឃុំតែងតែចុះមកបញ្ចុះបញ្ចូលនូវគោលនយោបាយបដិវត្តន៍ដល់ព្រះសង្ឃជាប្រចាំក្នុងរង្វង់ពីមួយទៅពីរសប្តាហ៍ម្តង ដើម្បីឱ្យព្រះសង្ឃទាំងនោះសឹកនឹងបានចូលរួមជាយុទ្ធជនតស៊ូជាមួយបដិវត្តន៍[៧]។ ក្នុងដំណាក់កាលនោះព្រះសង្ឃត្រូវបានអង្គការបង្ខំឱ្យធ្វើការដូចគ្រហស្ថដែរ។ នៅស្រុកត្រាំកក់ ខេត្តតាកែវ ក្នុងដំណាក់កាលរណសិរ្សតស៊ូនេះ ព្រះសង្ឃត្រូវបានអង្គការកេណ្ឌយកមកឱ្យធ្វើពលកម្មលើកទំនប់ដូចប្រជាជនដែរ។ ទំនប់ដែលព្រះសង្ឃបានចូលរួមលើកនោះមានឈ្មោះថា ***ទំនប់លោក*** រហូតមកដល់សព្វថ្ងៃ។ ការធ្វើបែបនេះ ក្នុងន័យធ្វើឱ្យព្រះសង្ឃណាមិនអាចទ្រាំទ្របាន ត្រូវតែលាចាកសិក្ខាបទដើម្បីចូលបម្រើអង្គការដែរ។

តាមលោក សុខ មឿន នៅខេត្តព្រៃវែង ជាអ្នករួចជីវិតពីស្លាប់នៃរបបកម្ពុជាប្រជាធិបតេយ្យម្នាក់ មានប្រសាសន៍ថា នៅតំបន់ដែលលោករស់នៅ ព្រះសង្ឃចាប់ផ្តើមអវត្តមានតាំងពីឆ្នាំ១៩៧៣រហូតដល់ពេញមួយរបបកម្ពុជាប្រជាធិបតេយ្យតែម្តង[៨]។

ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ក្នុងពេលដែលពុទ្ធសាសនានិងសាសនាដទៃទៀតត្រូវបានលុបបំបាត់ចោលទូទាំងប្រទេសនោះ មានព្រះសង្ឃមួយអង្គព្រះនាម ប៉ែន សេន បានស្ថិតនៅជាសង្ឃរហូតដល់ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ។ រឿងរ៉ាវរបស់ព្រះអង្គ ជារឿងរ៉ាវដែលអ្នកភូមិជើងធ្នុក ឃុំតាំងក្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម បានដឹងឮគ្រប់ៗគ្នា។ តាមលោកតា កៅ ធិន ជាអាចារ្យវត្តសុវណ្ណគីរី និងត្រូវ

---

[៥] អ៊ិត សារិន : *ស្រណោះព្រលឹងខ្មែរ!* ភ្នំពេញ, រោងពុម្ពពន្លឺឯករាជ្យ បោះពុម្ពលើកទី១ ឆ្នាំ១៩៧៣ ទំព័រ៤៦-៤៧។

[៦] សម្ភាសន៍ លោក អ៊ូច ហឿន អតីតអ្នកបួសក្នុងឆ្នាំ១៩៧២ នៅភូមិត្រពាំងឈើទាល ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ, ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៧។

[៧] សម្ភាសន៍ លោក ជាល ហុន អតីតអ្នកបួសក្នុងឆ្នាំ១៩៧២ នៅភូមិត្រពាំងឫស្សី ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ, ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៧។

[៨] ឡេង ម៉ាលី : *សាសនានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ភាគ៧៤)* វិទ្យុអាស៊ីសេរី (RFA) ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០០៨។

ជាប្អូនជីដូនមួយរបស់ព្រះតេជគុណ ប៉ែន សេន បានរៀបរាប់ថា ខ្មែរក្រហមបានគ្រប់គ្រងតំបន់ខាងលើនេះតាំងពីមុនឆ្នាំ១៩៧៥ ហើយបានបង្ខំព្រះសង្ឃឱ្យធ្វើស្ពាន ធ្វើស្រែបង្កបង្កើនផលជាមួយប្រជាជន។ ព្រះសង្ឃអង្គខ្លះជិះកង់យកនំកាតំនិងមាន់ទៅឱ្យកងទ័ពនៅសមរភូមិមុខទៀតផង[៩]។

ជារួមយើងឃើញថា ក្នុងដំណាក់កាលសង្គ្រាមរវាងចលនារណសិរ្សតស៊ូប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែរ អង្គការខ្មែរក្រហមបានចាមផ្ដើមធ្វើទុកបុកម្នេញមកលើពុទ្ធសាសនាក៏ដូចសាសនាដទៃទៀតដែរ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក្នុងដំណាក់កាលនេះផ្នែកមនោគមវិជ្ជាបដិវត្តន៍របស់បក្សកុម្មុយនីស្តកម្ពុជាហាក់ដូចជាមិនទាន់បដិសេធទៅលើជំនឿពុទ្ធសាសនាទាំងស្រុងនៅឡើយទេ ព្រោះពេលនោះជាដំណាក់កាលប្រមូលកម្លាំងចូលរួមក្នុងចលនាតស៊ូ។ ពួកគេត្រូវការកម្លាំងពីប្រជាជនគ្រប់ស្រទាប់ជាន់ថ្នាក់ទាំងព្រះសង្ឃ បញ្ញវន្ត កម្មករ កសិករ យុវជន យុវនារីឱ្យចូលរួមក្នុងចលនាតស៊ូបដិវត្តន៍។ ក្នុងស្មារតីនេះ ខ្លឹមសារនៃចម្រៀងបដិវត្តន៍ក៏នៅរក្សាជំហរចូលរួមចំណែករបស់ព្រះសង្ឃក្នុងការតស៊ូបដិវត្តន៍ផងដែរ។ ជាក់ស្តែងតាមរយៈបទចម្រៀង ***ទង់ក្រហមបដិវត្តន៍*** ខ្លឹមសារនៃបទចម្រៀងនៅបានលើកឡើងពីព្រះសង្ឃក្នុងកិច្ចការតស៊ូដូចប្រជាជននិងបញ្ញវន្តផងដែរ ៖

*«ឈាមក្រហមឆ្អៅ ក្រាលនៅលើប្រថពី ឈាមដែលពលី រំដោះប្រជាជន ឈាមកម្មករ កសិករ បញ្ញាជន ឈាមយុវជន ព្រះសង្ឃ ហើយនិងនារី ឈាមគួចអណ្តែត ត្រសែតលើមេឃា ប្រែក្លាយជាទង់ក្រហមបដិវត្តន៍។ ទង់ក្រហម អណ្តែតហើយ មិត្តយើងអើយ ពុះពារសម្រុកវាយខ្លាំង ទង់ ក្រហម អណ្តែតហើយ កំហឹងគ្មានស្បើយ បក់បោកដូចព្យុះសង្ឃរា ទង់ក្រហម អណ្តែតហើយ កុំទុកឡើយ ចក្រពត្តិប្រតិកិរិយា កម្ទេចឱ្យអស់ពីកម្ពុជា ពុះពារសម្រុក សម្រុកជ័យជម្នះ ជ័យជម្នះ ជ័យជម្នះ។»*

## ២.៣- ជំនឿពុទ្ធសាសនាក្រោយជោគជ័យ១៧ មេសា ១៩៧៥

ចលនាតស៊ូរបស់រណសិរ្សនៃខ្មែរក្រហមបានទទួលជ័យជម្នះលើរបបសាធារណរដ្ឋនាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ អង្គការបក្សកុម្មុយនីស្តបានចាត់ទុកថា ជ័យជម្នះនេះជាជោគជ័យដ៏មហាធំធេងក្នុងប្រវត្តិនៃការតស៊ូរបស់ខ្លួន។ អង្គការបានអះអាងថា បដិវត្តន៍ប្រជាជាតិ-ប្រជាធិបតេយ្យត្រូវបានចប់សព្វគ្រប់ ហើយត្រូវបន្តធ្វើបដិវត្តន៍សង្គមនិយម។

ក្រោមការគ្រប់គ្រងនៃបក្សកុម្មុយនីស្តកម្ពុជាដឹកនាំដោយ ប៉ុល ពត ច្បាប់រដ្ឋធម្មនុញ្ញថ្មីមួយត្រូវបានបង្កើតឡើងនិងប្រកាសឱ្យប្រើនាថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ ដោយកំណត់ឈ្មោះប្រទេសជាផ្លូវការថា ***កម្ពុជាប្រជាធិបតេយ្យ***។ មកដល់ដំណាក់កាលនេះ អង្គការបក្សកុម្មុយនីស្តកម្ពុជាដែលមាន ប៉ុល ពត ជាមគ្គុទេសក៍នោះបានប្រកាសក្នុងគោលនយោបាយកសាងប្រទេសថាត្រូវធ្វើបដិវត្តន៍សង្គមនិយម។ អ្វីៗមានការប្រែប្រួលទាំងស្រុង បន្ទាប់ពីការប្រកាសឱ្យប្រើនូវរដ្ឋធម្មនុញ្ញថ្មីនៃកម្ពុជាប្រជាធិបតេយ្យត្រង់ជំពូក៥ មាត្រា៥ ចែងថា *សភាតំណាងប្រជាជនកម្ពុជាមានសមាជិកទាំងអស់២៥០នាក់ តំណាងកសិករ១៥០នាក់ តំណាងកម្មករនិង*

---

[៩] សូមមើល ព្រំ ផល្លា : «ព្រះតេជគុណ ប៉ែន សេន ព្រះសង្ឃក្នុងរបបខ្មែរក្រហម» នៅក្នុង : ***ទស្សនាវដ្តីស្វែងរកការពិត*** មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ៥៤ ខែមិថុនា ឆ្នាំ២០០៤ ទំព័រ១៨-១៩។

*ពលករផ្សេងទៀត៥០នាក់ តំណាងកងទ័ពបដិវត្តន៍៥០នាក់* [១០]។ តាមរដ្ឋធម្មនុញ្ញនេះ វណ្ណៈសង្គមដែលសំខាន់ មានតែបីគឺ កសិករ កម្មករ និងកងទ័ព ដែលក្នុងនោះកសិករជាកម្លាំងស្នូល។

ស្របតាមខ្លឹមសារនៃរដ្ឋធម្មនុញ្ញថ្មីនេះ ចម្រៀងជាតិថ្មីនៃកម្ពុជាប្រជាធិបតេយ្យក៏មានការប្រែប្រួលផ្នែកអត្ថន័យដែរ។ ក្នុងដំណាក់កាលរណសិរ្សតស៊ូជាមួយរបបសាធារណរដ្ឋខ្មែរដឹកនាំដោយ លន់ នល់នោះ បទចម្រៀងទង់ក្រហមបដិវត្តន៍មានអត្ថន័យបានរៀបរាប់ពីឈាមអ្នកតស៊ូ ដូចជា ...*ឈាមកម្មករ កសិករ បញ្ញាជន ឈាមយុវជន ព្រះសង្ឃហើយនិងនារី ...*។ ឯអត្ថន័យនៃចម្រៀងជាតិថ្មីយើងឃើញមានតែ ...*ឈាមកម្មករ កសិករដ៏ឧត្តម ឈាមយុទ្ធជន យុទ្ធនារីបដិវត្តន៍*... មានន័យថា ព្រះសង្ឃនៃពុទ្ធសាសនាមិនត្រូវបានអង្គការនឹកឃើញនិងលើកឡើងឬសម្តែងការដឹងគុណទៀតទេ។

ព្រះពុទ្ធសាសនាក៏ដូចជាសាសនាដទៃទៀតដែរត្រូវបានអង្គការចាត់ទុកថា ជាកម្អែលសង្គមចាស់ហើយត្រូវតែកម្ទេចចោលឱ្យអស់។ ក្រោយជ័យជម្នះនៅថ្ងៃ១៧ មេសា ១៩៧៥ អង្គការបានផ្សឹកព្រះសង្ឃដោយបង្ខំ បើព្រះសង្ឃអង្គណាដែលនៅតែរឹងរូសមិនព្រមសឹក ត្រូវបានអង្គការចាប់ដាក់គុកហើយធ្វើគត។ បន្ទាប់ពីផ្សឹករួច អង្គការតម្រូវឱ្យអតីតសង្ឃទាំងនោះទៅធ្វើការងារកសិកម្មដូចប្រជាជនដទៃទៀតនៅក្នុងប្រទេសកម្ពុជាដែរ។ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យត្រង់ជំពូកទី១៥ មាត្រាទី២០ បានចែងថា*ប្រជាជនកម្ពុជាគ្រប់រូបមានសិទ្ធិជឿជំនឿឬសាសនាណាក៏បាន ហើយក៏មានសិទ្ធិមិនមានជំនឿលើអ្វីឬក៏មិនជឿសាសនាណាក៏បាន។ មិនអនុញ្ញាតឱ្យមានសាសនាប្រតិកិរិយា ដែលបំផ្លិចបំផ្លាញកម្ពុជាប្រជាធិបតេយ្យនិងប្រជាជនកម្ពុជាដាច់ខាត* [១១]។ គ្រប់ជំនឿនិងសាសនាទាំងអស់ ទោះព្រះពុទ្ធសាសនាក្តី អ៊ិស្លាមសាសនាក្តី គ្រិស្តសាសនាក្តី ឬជំនឿទៅលើអារក្សអ្នកតាតាំងពីបរមបុរាណមកក្តី ក៏ត្រូវបានអង្គការចាត់ទុកថា ជាសាសនាប្រតិកិរិយា ហើយត្រូវតែកម្ទេចចោល។ ជំនឿព្រះពុទ្ធសាសនាដែលប្រជាជនកម្ពុជាភាគច្រើនបំផុតគោរពបូជា និងចាត់ជាគ្រឹះនៃវប្បធម៌ខ្មែររាប់ពាន់ឆ្នាំមកហើយនោះ បានក្លាយជាឧបសគ្គដ៏ធំនៅក្នុងការកសាងបដិវត្តន៍ និងជាឧបករណ៍រាំងស្ទះដល់ដំណើរឆ្ពោះទៅរកបដិវត្តន៍សង្គមនិយមពិតប្រាកដរបស់បក្សកុម្មុយនីស្តកម្ពុជា។ អង្គការបានបង្ហាត់បង្រៀនកងទ័ព កម្មាភិបាល ប្រជាជនឱ្យកសាងខ្លួនដោយធ្វើការងារនិងគោរពវិន័យអង្គការ មិនមែនកសាងខ្លួនតាមបែបសមាធិក្នុងបន្ទប់ទេ។ អង្គការបានវាយប្រហារយ៉ាងធ្ងន់ធ្ងរទៅលើលទ្ធិសាសនា មិនតែប៉ុណ្ណោះអង្គការថែមទាំងបញ្ជាឱ្យវាយកម្ទេចពុទ្ធបដិមាតាមវត្តអារាមនានា ដុតគម្ពីរធម៌ បង្ខំព្រះសង្ឃឱ្យលាចាកសិក្ខាបទ ហើយប្រែក្លាយវត្តអារាមឱ្យទៅជាឃ្លាំងដាក់សម្ភារៈ ជាជង្រុកស្រូវ ជាកន្លែងចិញ្ចឹមសត្វ ជាមន្ទីរឃុំឃាំងមនុស្ស ឬត្រូវកម្ទេចចោលទាំងស្រុង។ អង្គការហាមមិនឱ្យប្រជាជនបួងសួង ប្រារព្ធពិធីសែនព្រេន ដែលបង្ហាញពីមនោសញ្ចេតនាក្នុងការគោរពបូជាសាសនានោះទេ។ អង្គការចាត់ទុកសាសនាជាអាភៀន ហើយព្រះសង្ឃគឺជាជនបញ្ញើក្អែក ជាព្រូនសង្គម ទុកក៏មិនចំណេញដកចេញក៏មិនខាត។ អង្គការបានពន្យល់ប្រាប់ប្រជាជនថា គ្មានព្រះ គ្មានខ្មោចលង គ្មានអបិយជំនឿទេ។ សាសនាដទៃទៀតក៏មានវាសនាមិនខុសពីព្រះពុទ្ធសាសនាដែរ វិហារសាសនាគ្រិស្តមួយចំនួន

---

[១០] សូមមើល : ***រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ*** ភ្នំពេញ, ឆ្នាំ១៩៧៦ ទំព័រ៦-៧។

[១១] សូមមើល : ***រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ*** ដ.ឯ.ម. ទំព័រ១៥-១៦។

ត្រូវបានវាយកម្ទេចចោល និងត្រូវបានអង្គកាចាត់ទុកគ្រិស្តសាសនា ជាសាសនារបស់ចក្រពត្តិ ដែលជាសត្រូវធំបំផុតរបស់បដិវត្តន៍។ មេដឹកនាំសាសនាអ៊ិស្លាមជាច្រើនត្រូវបានសម្លាប់ ហើយបរិស័ទអ៊ិស្លាមត្រូវបានបង្ខំឱ្យរស់នៅលាយឡំជាមួយប្រជាជនខ្មែរ បង្ខំឱ្យហូបសាច់ជ្រូក និងត្រូវប្តូរឈ្មោះឱ្យមានលក្ខណៈជាខ្មែរវិញថែមទៀតផង។ តាមព្រះតេជព្រះគុណ ខឹម សឿង បានមានសង្ឃដីកាថា *«គេបានចាត់ទុកព្រះសង្ឃជាវណ្ណៈអនុជន ជិះជាន់គេសម្ងំសុខ និងចាត់ទុកពុទ្ធសាសនាជាសាសនាជិះជាន់ បានជាត្រូវគេបំបិទចោល និយាយរួមព្រះពុទ្ធសាសនាហ្នឹងតែម្តងត្រូវតែកម្ទេចចោល ពួកនេះបានហៅព្រះសង្ឃថា ជាឈ្លើងជញ្ជក់ឈាមគេ»*[១២] ។ សាក្សីដែលបានរួចជីវិតពីស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យបាន ឱ្យដឹងថា *នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពួកខ្មែរក្រហមបានចាត់ទុកព្រះពុទ្ធបដិមាថាគ្រាន់តែជាស៊ីម៉ង់ត៍ប៉ុណ្ណោះ ថែមទាំងបានលើកពាក្យស្លោកថា កម្ទេចព្រះមួយអង្គចំណេញស៊ីម៉ង់ត៍មួយបាវ។អង្គការបានពន្យល់ថា ព្រះសង្ឃជាពួកវណ្ណៈជិះជាន់ មិនគួរឱ្យគោរពទេ មានតម្លៃមិនស្មើនឹងកូនក្មេងផង បន្ថែមលើការកំណត់របស់អង្គការនេះ មានពាក្យមួយឃ្លាទៀតដែលមានន័យបង្អាប់ព្រះពុទ្ធសាសនាដោយបានលើកឡើងថា ថ្វាយបង្គំព្រះដូចថ្វាយបង្គំស៊ីម៉ង់ត៍ ថ្វាយបង្គំលោកសង្ឃដូចថ្វាយបង្គំកូនអ្នកស្រុក*[១៣] ។

ទោះជាយ៉ាងនេះក៏ដោយលោក នួន ជា ជាអតីតមេដឹកនាំកំពូលនៃរបបកម្ពុជាប្រជាធិបតេយ្យធ្លាប់មានឋានៈជាប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យនិងជាមេមនោគមវិជ្ជានៃបក្សកុម្មុយនីស្តកម្ពុជា បានឆ្លើយការពារខ្លួនក្នុងពេលដែលសហព្រះរាជអាជ្ញាអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសួរកាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ថា កម្ពុជាប្រជាធិបតេយ្យមិនបានបំផ្លាញព្រះពុទ្ធសាសនាទេ អ្វីដែលកម្ពុជាប្រជាធិបតេយ្យបានធ្វើនោះជាការដោះស្រាយនូវអ្វីដែលចាស់ឱនថយ ដើម្បីកសាងថ្មីប៉ុណ្ណោះ។ លោក នួន ជា បានហៅសំណួររបស់លោកសហព្រះរាជអាជ្ញាអន្តរជាតិដែលសួរពីភស្តុតាងនៃការបំផ្លាញពុទ្ធសាសនាក្នុងសម័យកម្ពុជាប្រជាធិបតេយ្យថា ជាការមិនយល់ដល់លទ្ធិព្រះពុទ្ធសាសនា ហើយកុំមកធ្វើការវាយប្រហារមកលើកម្ពុជាប្រជាធិបតេយ្យ លោកថាគ្មានវិធានការណាទៅបិទសាសនាទេ។ លោក នួន ជា បាននិយាយការពារដល់ការវាយកម្ទេចវត្តអារាមក្នុងសម័យកម្ពុជាប្រជាធិបតេយ្យថា *ការគោរពពុទ្ធសាសនាមិនចាំបាច់ទៅវត្តអារាមទេ គឺការប្រតិបត្តិក្នុងចិត្តបានហើយ។ កាលពីសម័យព្រះពុទ្ធអង្គមានកុដិឯណា ព្រះលោកប្រសូត្រក្នុងព្រៃ ហើយបានត្រាស់ដឹងក្នុងព្រៃ។* តាមទស្សនៈរបស់លោក នួន ជា *ការមានវត្តអារាមមិនមែនជាខ្លឹមសារបេះដូងនៃព្រះពុទ្ធសាសនាពិតប្រាកដទេ។* លោក នួន ជា បានយល់ថា បេះដូងនៃពុទ្ធសាសនាគឺ *សីល សមាធិ បញ្ញា* ទាំងនេះអ្នកប្រតិបត្តិត្រូវអនុវត្តក្នុងជីវភាពប្រចាំថ្ងៃ មិនមែនវត្តអារាមសំខាន់ទេ[១៤]។

ទាក់ទងនឹងការផ្សឹកព្រះសង្ឃនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោក នួន ជា បានលើកឡើងថា *«សង្គមពេលនោះវាប្រែប្រួលជាសង្គមសហករណ៍ ព្រះសង្ឃលោកក៏ត្រូវកែប្រែគំនិត លោកក៏ត្រូវសម្រួលជីវិត*

---

[១២] ឡេង ម៉ាលី : ***សាសនានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ភាគ៧៤)*** វិទ្យុអាស៊ីសេរី (RFA) ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០០៨។

[១៣] ឡេង ម៉ាលី : ***សាសនានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ភាគ៧៤)*** វិទ្យុអាស៊ីសេរី (RFA) ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០០៨។

[១៤] គង់ សុឋានរិទ្ធ : ***ខ្មែរក្រហមមិនបំផ្លាញព្រះពុទ្ធសាសនាទេ*** វីអូអេខ្មែរ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១។

*របស់ព្រះអង្គទៅតាមនោះដែរ។ នេះមិនមែនយើងមានចេញច្បាប់មិនឱ្យបួសទេយើងគិតពីរឿងស្រែសិន»*[១៥] ។

មេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យជឿជាក់ថា សាសនាគឺជាឧបសគ្គចម្បងចំពោះគោលបំណងដែលពួកគេចង់ឱ្យសម្រេចបានក្នុងការកសាងបដិវត្តន៍មួយមហាលោតផ្លោះមហាអស្ចារ្យ។ដោយសារតែហេតុផលនេះហើយទើបពួកគេរិះរកមធ្យោបាយ ដើម្បីបំបាត់ចោលនូវការប្រតិបត្តិសាសនានានា នៅទូទាំងប្រទេសកម្ពុជា ហើយដាក់ការគោរពបូជាចំពោះអង្គការបដិវត្តន៍ជំនួសឱ្យការគោរពបូជាចំពោះសាសនាទៅវិញ។

អង្គការបានបំបែរប្រទេសកម្ពុជាឱ្យមនុស្សគ្រប់ៗគ្នាត្រូវស្ថិតនៅក្រោមវិន័យអង្គការនិងត្រូវមានស្វាមីភក្តិចំពោះអង្គការ ដូចដែលព្រះសង្ឃធ្លាប់មានចំពោះព្រះចៅអធិការឬមេវត្តដូច្នោះដែរ។ តាមការកំណត់អង្គការបានទាមទារឱ្យប្រជាជនគ្រប់រូបមានស្វាមីភក្តិចំពោះបដិវត្តន៍ដោយឥតងាករេ ដូចដែលប្រជាជនធ្លាប់គោរពនិងមានជំនឿចំពោះព្រះសង្ឃដែរ។

ដូចនេះ យើងឃើញច្បាស់ថា អង្គការបានបំបិទជំនឿពុទ្ធសាសនា ប្រពៃណី ទំនៀមទម្លាប់ផ្សេងៗរបស់ប្រជាជនដែលគោរពប្រតិបត្តិតាំងពីបុរាណកាលមក គឺក្នុងបំណងមួយការបង្វែរសតិអារម្មណ៍ប្រជាជនឱ្យមកគោរពវិន័យអង្គការបដិវត្តន៍តែមួយគត់ប៉ុណ្ណោះ។

## ៣- ផលប៉ះពាល់នៃការអវត្តមានជំនឿពុទ្ធសាសនាក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ

ប្រជាជនកម្ពុជាបានទទួលយកនិងប្រតិបត្តិជំនឿពុទ្ធសាសនាថេរវាទទៅតាមមាគ៌ាប្រតិបត្តិនៃមគ្គប្រកបអង្គ៨ក្នុងដំណើរឆ្ពោះទៅរកការរំដោះទុក្ខមានជាតិទុក្ខជាដើម។

រហូតមកដល់សព្វថ្ងៃ ពុទ្ធសាសនាបានរីករាលដាលកាន់តែខ្លាំងឡើងជាងមុន គឺមានអ្នកកាន់ពុទ្ធសាសនានៅទ្វីបអឺរ៉ុបក៏ដូចជានៅអាមេរិកផងដែរ។ បុគ្គលដែលចូលមកកាន់និងប្រតិបត្តិពុទ្ធសាសនាភាគច្រើនជាបញ្ញវន្តថែមទៀតផង[១៦]។ កាលណាវិទ្យាសាស្ត្រកាន់តែលូតលាស់ ពុទ្ធសាសនាក៏កាន់តែលូតលាស់ដែរ ព្រោះពុទ្ធសាសនាក៏អប់រំមនុស្សឱ្យយល់នូវការពិតទាំងឡាយដែលជាសច្ចសកលដែរ គឺការពិតទូទៅបានដល់អរិយសច្ច៤ មានទុក្ខសច្ចជាដើម ជាមាគ៌ាណែនាំអ្នកប្រតិបត្តិឱ្យយល់និងឆ្ពោះទៅរកការរំដោះទុក្ខនៃមនុស្សទាំងពួង។ ពុទ្ធសាសនាក៏ដូចវិទ្យាសាស្ត្រដែរ គឺនិយាយពីទំនាក់ទំនងហេតុនិងផល ដែលគេអាចធ្វើពិសោធបាន បើហេតុកើតឡើងយ៉ាងណា ផលក៏កើតឡើងតាមហេតុរបស់វាដែរ។

យើងជាអ្នកប្រកាន់យកជំនឿពុទ្ធសាសនាបានដឹងច្បាស់ថា ខ្លឹមសារនៃទស្សនវិជ្ជាពុទ្ធសាសនាមានពាក្យប្រៀនប្រដៅដ៏សំខាន់គឺ*ធម៌អហិង្សា ការមិនបៀតបៀនគ្នា* ដែលជាមូលដ្ឋានក្នុងការបង្កើតឱ្យមានសុខសន្តិភាពនៃពិភពលោក។ ក្នុងប្រវត្តិសាស្ត្រពិភពលោក យើងមិនធ្លាប់ឃើញបុគ្គលកាន់ជំនឿពុទ្ធសាសនាបង្ហូរឈាមគ្នាដោយមូលហេតុសាសនានេះកើតមានឡើងនៅទីកន្លែងណាមួយឡើយ។ ពុទ្ធសាសនាជាសាសនាសន្តិភាព យើងអាចយកពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធអង្គ ដូចជា ធម៌អហិង្សា ធម៌ព្រហ្មវិហារមាន*មេត្តា ករុណា មុទិតា និងឧបេក្ខា* ធ្វើជារូបមន្តសម្រាប់បំបាត់កំហឹង បំបាត់ការបង្ហូរឈាមគ្នា និងការកសាងសុខ

---

[១៥] ឡេង ម៉ាលី : ***សាសនានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ភាគ៧៤)*** វិទ្យុអាស៊ីសេរី (RFA) ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០០៨។

[១៦] ហុក សាវណ្ណ : ***តួនាទីរបស់ព្រះសង្ឃក្នុងសង្គមខ្មែរ*** ភ្នំពេញ, ឆ្នាំ២០០៨ ទំព័រទី១-២។

សន្តិភាពជូនមនុស្សក្នុងពិភពលោក។

នៅប្រទេសកម្ពុជា បើមានភូមិប្រជាជននៅទីកន្លែងណា តែងតែមានវត្តពុទ្ធសាសនានៅទីនោះផងដែរ។ មានន័យថា វត្តពុទ្ធសាសនាតែងមាននៅតាមភូមិ ឃុំ ស្រុក ខណ្ឌ ខេត្ត ក្រុង នៃព្រះរាជាណាកម្ពុជា។ ក្នុងការប្រតិបត្តិពុទ្ធសាសនា ប្រជាជនកម្ពុជាតែចាត់ទុកវត្តអារាមជាមជ្ឈមណ្ឌលរបស់ប្រជាជាតិខ្មែរសម្រាប់សិក្សានិងប្រតិបត្តិពិធីពុទ្ធសាសនា។ តាមទំនៀមទម្លាប់តាំងពីបុរាណមក ប្រជាជនខ្មែរតែងឱ្យកូនប្រុសចូលបួសរៀនក្នុងវត្តអារាម ដើម្បីរៀនធម៌ រៀនអក្សរសាស្ត្រនិងវិជ្ជាជីវៈផ្សេងៗទៀត។ លុះពេលលាចាកសិក្ខាបទបុគ្គលទាំងនោះត្រូវបានគេហៅ *អន្ទិត* ពាក្យនេះមានន័យថា *បណ្ឌិត* គឺអ្នកមានចំណេះដឹង មានចរិយាល្អ មានចិត្តបរិសុទ្ធ។ ទាំងនេះបញ្ជាក់ថា ព្រះសង្ឃដែលមានចំណេះដឹងខាងពុទ្ធសាសនា គឺមានចំណេះដឹងទាំងផ្នែកវប្បធម៌ ទាំងផ្នែកវិជ្ជាជីវៈ និងផ្នែកកិច្ចការសង្គមផង។ ព្រះសង្ឃនៃពុទ្ធសាសនាជាម្លប់នៃពុទ្ធបរិស័ទនៅពេលមានវិបត្តិផ្លូវចិត្ត ប្រជាជនពុទ្ធបរិស័ទតែងតែថ្វាយបង្គំព្រះសង្ឃឱ្យជួយដោះស្រាយ។ នៅតាមវត្តអារាមស្រុកស្រែចម្ការ ព្រះសង្ឃចិញ្ចឹមកូនប្រជាជនក្រីក្រ កុមារកំព្រាឱ្យបានសិក្សារៀនសូត្រ។ វត្តអារាមនៅទីក្រុងក៏មិនខុសពីវត្តអារាមនៅជនបទដែរ ព្រះសង្ឃបានផ្តល់កន្លែងឱ្យសិស្ស និស្សិតបានស្នាក់នៅដើម្បីរៀនសូត្រគឺបានជួយសម្រួលផ្នែកជីវភាព សម្រាលការលំបាកផ្សេងៗបានមួយផ្នែកផងដែរ។

ទាំងនេះបញ្ជាក់ថា វត្តអារាមនៃពុទ្ធសាសនាមានតួនាទីសំខាន់ណាស់ក្នុងការជួយសម្រួលដល់ជីវភាពរស់នៅក្នុងសង្គមមួយផ្នែករបស់ប្រជាពលរដ្ឋខ្មែរ។

ជាងនេះទៅទៀត យើងឃើញថា ពុទ្ធសាសនាក្នុងសង្គមខ្មែរមានវត្តអារាម មានព្រះសង្ឃ មានគម្ពីរផ្សេងៗក៏ជាអត្តសញ្ញាណជាតិនិងជាប្រភពដ៏សំខាន់ក្នុងផ្តល់ចំណេះដឹង បំណិនជីវិត សម្រាប់ប្រជាជនកម្ពុជាអាចរស់នៅនិងកសាងសង្គមជាតិរបស់ខ្លួនឱ្យមានភាពសុខដុមរមនាទាំងផ្លូវកាយ ទាំងផ្លូវចិត្តអស់រយៈកាលដ៏យូរមកហើយដែរ។

តើពេលអវត្តមានជំនឿពុទ្ធសាសនានារបបកម្ពុជាប្រជាធិបតេយ្យ ប្រទេសកម្ពុជាពេលនោះមានអ្វីកើតឡើងខ្លះ ?

នៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យបានចែងអំពីជំនឿពុទ្ធសាសនានេះថា *វប្បធម៌របស់កម្ពុជាប្រជាធិបតេយ្យ មានលក្ខណៈជាតិ ប្រជាជន និងចម្រើនស្អាតស្អំ ដើម្បីបម្រើភារកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជាឱ្យបានរុងរឿងសម្បូរសប្បាយ។ វប្បធម៌ថ្មីនេះប្រឆាំងដាច់ខាតនឹងវប្បធម៌ពុករលួយប្រតិកិរិយារបស់វណ្ណៈជិះជាន់ផ្សេងៗ និងរបស់អាណានិគមនិយម ចក្រពត្តិនិយមនៅកម្ពុជា*[១៧]។

សម័យកម្ពុជាប្រជាធិតេយ្យ រាល់សកម្មភាពទាំងឡាយដែលទាក់ទងនឹងវិស័យវប្បធម៌ត្រូវបានអង្គការបង្វែរទិសដៅទៅបម្រើបដិវត្តន៍បក្សកុម្មុយនីស្តកម្ពុជាទាំងអស់។

ពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ មានព្រះសង្ឃនៃពុទ្ធសាសនាក៏ដូចអិស្លាមសាសនិកមួយចំនួនត្រូវបានអង្គការបង្ខំឱ្យចូលរួមចំណែកធ្វើបដិវត្តន៍ដែរ។ កត្តានេះបានធ្វើឱ្យអ្នកទាំងនោះត្រូវតែបោះបង់ចោលជំនឿសាសនារបស់ពួកគេ ដើម្បីចូលរួមក្នុងតស៊ូខ្មែរក្រហម។ ក្រោយថ្ងៃជោគជ័យនៃចលនាតស៊ូរបស់ខ្មែរ

[១៧] សូមមើល : ***រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ*** ដ.ឯ.ម. ទំព័រ៥។

ក្រហម អង្គការបានផ្សឹកព្រះសង្ឃទាំងអស់ វត្តអារាមត្រូវបានបិទចោលទាំងស្រុង គម្ពីរផ្សេងៗត្រូវបំផ្លាញ។ តាមបរសាសន៍របស់លោក ព្រំ ហ៊ាង ជាប្រជាជននៅខេត្តកណ្តាល ដែលជាអ្នករួចជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យនេះ បានឱ្យដឹងថា *«គេមិនឱ្យមានជំនឿអីទេ គេថាបើទុកលោកសង្ឃ ត្រូវទុកវត្ត ហើយបើទុកវាំង ត្រូវទុកស្តេច។ សូម្បីតែម៉ែឪក៏គេមិនឱ្យគោរពផងពេលនោះ។ គេឱ្យសរសើរតែអង្គការរបស់គេ គេថាមានតែអង្គការរបស់គេបានមានគុណ។ គោរពអង្គការរបស់គេ ជឿតាមអង្គការរបស់គេ កុំឱ្យជឿអ្នកណាក្រៅពីអង្គការឱ្យសោះ។ អង្គការរបស់គេហ្នឹងហើយធំជាងអ្វីៗទាំងអស់»*[១៨]។

ការវាយប្រហារទៅលើសាសនារបស់អង្គការបដិវត្តន៍នៃបក្សកុម្មុយនីស្តកម្ពុជា មានន័យថាជាការវាយប្រហារទៅលើគ្រួសារនិងតម្លៃគ្រួសារនៃសង្គមខ្មែរដែរ។ អង្គការចង់កម្ទេចចោលទាំងស្រុងនូវតម្លៃទំនាក់ទំនងនិងឥរិយាបថនានាដែលមានមុនសម័យបដិវត្តន៍ ដើម្បីបង្កើតឡើងនូវតម្លៃថ្មី ទំនាក់ទំនងថ្មី មនុស្សថ្មី និងសង្គមថ្មីមួយទៅតាមមាគ៌ាបក្សកុម្មុយនីស្តកម្ពុជា។ ពួកគេក៏មិនអត់ឱនឱ្យដែរចំពោះអំណាចសីលធម៌ដែលព្រះសង្ឃបានប្រតិបត្តិនៅតាមជនបទស្រែចម្ការ ដោយគេចាត់ទុកថា អ្វីដែលជាជំនឿរបស់ប្រជាជននោះ ជាការប្រជែងនឹងអង្គការបដិវត្តន៍ដោយប្រយោល។

ពុទ្ធិក្នុងព្រះពុទ្ធសាសនា ពាក្យប្រៀនប្រដៅសំខាន់របស់ព្រះពុទ្ធគឺ *ធម៌អហិង្សា ការមិនបៀតបៀនគ្នា* ជាមូលដ្ឋានដែលធ្វើឱ្យកើតមានសន្តិភាព។ សង្គមកម្ពុជាធ្លាប់បានឆ្លងកាត់វិបត្តិនយោបាយជាច្រើនសម័យកាលមកហើយ រហូតមកដល់ដំណាក់កាលមួយខ្មែរសម្លាប់ខ្មែរគ្នាឯងយ៉ាងឃោរឃៅបំផុត។ អំពើអមនុស្សធម៌ទាំងនោះបានដើរផ្ទុយស្រឡះទៅពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ។ ការបំផ្លាញពុទ្ធសាសនានៃរបបកម្ពុជាប្រជាធិបតេយ្យ គឺជាការបំផ្លាញខ្លួនឯង បំផ្លាញសង្គមជាតិ បំផ្លាញអ្វីៗទាំងអស់។

ពាក្យថា ***វត្ត*** ជាភាសាខ្មែរត្រូវនឹងភាសាបាលីថា ***វត្តំ*** ប្រែថា *ទីកន្លែងសម្រាប់គោរពបូជា ទីកន្លែងសម្រាប់ព្រះសង្ឃគង់នៅ*[១៩]។

ពាក្យ ***អារាម*** មានន័យថា *ប្រទេសឬទីដែលនាំទឹកចិត្តឱ្យសប្បាយរីករាយ*[២០]។

ពាក្យទាំងពីរនេះប្រជាជនខ្មែរតែងតែនិយាយរួមបញ្ចូលគ្នាទៅជា ***វត្តអារាម***។ មានន័យថា ជាទីសម្រាប់គោរពបូជាផងនិងផ្តល់នូវចិត្តសប្បាយរីករាយផង។ កាលណាអ្នកណាម្នាក់មានកង្វល់ផ្លូវចិត្ត បើគេបានចូលវត្ត គេនឹងបានទាញអារម្មណ៍គេរីករាយផ្លូវចិត្តក្នុងភាពស្ងប់។

ពាក្យថា ***ព្រះសង្ឃ*** មានន័យថា *ក្រុមឬពួករបស់បុព្វជិតឬអ្នកបួស គឺភិក្ខុនិងសាមណេរ ដែលលះបង់ពីភេទជាគ្រហស្ថមកបួសជាឧត្តមភេទក្នុងពុទ្ធសាសនា*។

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពេលអង្គការដឹកនាំបានបំបាត់ព្រះពុទ្ធសាសនាទាំងស្រុង តើពេលនោះ សង្គមយើងបានបាត់បង់អ្វីខ្លះ? ហើយមានអ្វីកើតឡើងខ្លះ?

ជាការពិត ពេលសង្គមពុំមានជំនឿសាសនា វាបង្កឱ្យមានផលប៉ះពាល់ដូចតទៅ៖

---

[១៨] ឡេង ម៉ាលី : ***សាសនានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ភាគ៧៤)*** វិទ្យុអាស៊ីសេរី (RFA) ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០០៨។

[១៩] ហុក សាវណ្ណ : ***តួនាទីរបស់ព្រះសង្ឃក្នុងសង្គមខ្មែរ*** ជ.ឯ.ម. ទំព័រទី១៣។

[២០] -ដ- ទំព័រទី១៣។

- អង្គការបំបាត់ពុទ្ធសាសនា មានន័យថា បំបាត់ធម៌អហិង្សា បំបាត់ការសន្តោសប្រណី បំបាត់ការអធ្យាស្រ័យ បំបាត់មនុស្សធម៌ ធ្វើឱ្យសង្គមគ្មានគុណធម៌ គ្មានច្បាប់ទម្លាប់ គ្មានការចែករំលែកសុខទុក្ខគ្នាទៅវិញទៅមក។ ជាក់ស្តែងនៅក្នុងសង្គមនៃរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនរស់ដោយគ្មានសិទ្ធិសេរីភាព រស់នៅដោយភ័យខ្លាចរស់នៅក្រោមអំពើព្រៃផ្សៃយ៉ាងវេទនាជាទីបំផុត។
- អង្គការបំបាត់ពុទ្ធសាសនា មានន័យថា អង្គការបំបាត់វត្តអារាម កាលណាគ្មានវត្តអារាមគឺគ្មានសេចក្តីសប្បាយរីករាយ ព្រោះវត្តអារាមនេះជាទីផ្តល់នូវចិត្តសប្បាយរីករាយ។ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ប្រជាជនរស់នៅក្នុងភាពភ័យខ្លាច រង់ចាំតែពេលស្លាប់ប៉ុណ្ណោះ។
- អង្គការបំបាត់វត្តអារាម មានន័យថា បំបាត់អត្តសញ្ញាណជាតិ ដូចជា វប្បធម៌ អក្សរសាស្ត្រ សាលារៀន ប្រវត្តិសាស្ត្រ ក្បួនគម្ពីរផ្សេងៗ ជាដើម។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ យើងពុំមានឃើញប្រជាជនធ្វើបុណ្យតាមប្រពៃណីអ្វីទេ បុណ្យដែលសំខាន់ជាងគេនៃកម្ពុជាប្រជាធិបតេយ្យគឺ*ថ្ងៃជ័យជម្នះ១៧ មេសា ១៩៧៥*ដែលអង្គការបានកំណត់យកជាថ្ងៃបុណ្យចូលឆ្នាំទៀតផង។
- អង្គការបំបាត់វត្តអារាម មានន័យថា បំបាត់សីលធម៌ចាស់ទុំ ទំនៀមទម្លាប់ប្រពៃណី ព្រោះព្រះសង្ឃជាអ្នកប្រៀនប្រដៅសីលធម៌និងជាអ្នកអប់រំ បង្ហាញផ្លូវនៃជីវិតរស់នៅក្នុងសង្គមដល់ពុទ្ធបរិស័ទ។ ផ្ទុយទៅវិញ អង្គការបានបង្ហំឱ្យប្រជាជន*ប្តេជ្ញា គោរពដើរតាមតែមាគ៌ាបដិវត្តន៍ និងវិន័យអង្គការដោយឥតងាករេ។*
- អង្គការបំបាត់វត្តអារាម មានន័យថា បំបាត់នូវសាមគ្គីភាពក្នុងសង្គម បំបាត់នូវទំនាក់ទំនងសង្គមក្នុងរបបកម្ពុជាប្រជាធិបតេយ្យប្រជាជនរស់នៅក្រោមគោលជំហរដែលកំណត់ដោយអង្គការថា *ឯករាជ្យ-ម្ចាស់ការ ក្បាលអាណា សក់អាហ្នឹង ខ្លួនទីពឹងខ្លួន ជាដើម។*

ដូចនេះ យើងអាចនិយាយបានថា តាំងពីសម័យអតីតកាលរហូតមកដល់បច្ចុប្បន្ននេះ ព្រះពុទ្ធសាសនាបានរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសង្គមជាតិនៃកម្ពុជាគ្រប់វិស័យ។ ទោះបីសង្គមមនុស្សបច្ចុប្បន្ន ជាសម័យកាលនៃអ្នកវិទ្យាសាស្ត្រក៏ដោយក៏យើងមិនអាចអភិវឌ្ឍសង្គមដោយគ្មានជំនឿសាសនាបានដែរ។ ការបាត់បង់ជំនឿពុទ្ធសាសនាមួយរយៈនៃសម័យកម្ពុជាប្រជាធិបតេយ្យបាននាំមកនូវវិបត្តិធ្ងន់ធ្ងរដល់ប្រទេសកម្ពុជា។ ក្នុងបរិបទនៃមនោគមវិជ្ជាបដិវត្តន៍បែបឆ្វេងនិយមជ្រុលនៃបក្សកុម្មុយនីស្តកម្ពុជា បានធ្វើឱ្យកុមារ យុវជន ក៏ដូចជាជនបដិវត្តន៍មួយចំនួនមានចរិតដាច់ខាត មិនអាចសម្រុះសម្រួលបានបាត់បងសីលធម៌ សុជីវធម៌ គុណធម៌ ការសន្តោស ការអធ្យាស្រ័យក្នុងសង្គម ជាពិសេសការធ្វើឱ្យប្រទេសធ្លាក់ក្នុងភ្នក់ភ្លើងសង្គ្រាមកាប់សម្លាប់ជាតិសាសន៍ឯងដោយមិនញញើតដៃ។

ព្រះសង្ឃ វត្តអារាម បានដើរតួយ៉ាងសំខាន់ក្នុងរួមចំណែកស្តារឡើងវិញនូវអ្វីដែលបាត់បង់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដូចជាក្នុងអំឡុងពេលដែលប្រទេសជួបវិបត្តិសង្គ្រាមស៊ីវិល រួមចំណែកបណ្តុះបណ្តាលនូវមូលដ្ឋានគ្រឹះនៃសីលធម៌ សុជីវធម៌ គុណធម៌ មនុស្សធម៌ដល់ខេមរជនទាំងឡាយ ពិសេសយុវជនដែលជាទំពាំងស្នងឫស្សីជាតិទៅអនាគត។

## សន្និដ្ឋាន

សរុបមក យើងឃើញថា វត្តមាននៃពុទ្ធសាសនានៅក្នុងប្រទេសកម្ពុជាយើងមានពីយូរយារណាស់មកហើយ រហូតរដ្ឋាភិបាលបានចាត់ទុកពុទ្ធសាសនាជាសាសនារបស់រដ្ឋថែមទៀតផង។ តាមការប្រតិបត្តិជំនឿពុទ្ធសាសនានេះប្រជាជនខ្មែរតែងតែបានទទួលការអប់រំបន្ទុំចិត្តតាមការទូន្មានប្រៀនប្រដៅនៃពុទ្ធោវាទដើម្បីទទួលបាននូវសេចក្តីសុខផ្ទាល់ខ្លួនក៏ដូចក្នុងសង្គមជាតិទាំងមូល។

ការអវត្តមាននៃជំនឿពុទ្ធសាសនា ដោយសារការហាមឃាត់ពីសំណាក់អង្គការដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ បានជះឥទ្ធិពលមិនល្អយ៉ាងខ្លាំងដល់សតិអារម្មណ៍ និងការរស់នៅរបស់ប្រជាជនកម្ពុជាទាំងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដូចជាសម័យបន្តបន្ទាប់។ ភាពអវិជ្ជមានដែលកើតចេញពីការអវត្តមាននៃជំនឿពុទ្ធសាសនាក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលនៅសេសសល់ ជាបញ្ហាមួយដ៏សំខាន់ដែលសង្គមទាំងមូលត្រូវតែរួមគ្នាយកចិត្តទុកដាក់និងដោះស្រាយឱ្យបាន។ អ្វីដែលបានកើតឡើងក្នុងប្រវត្តិសាស្ត្រនៃសង្គមយើងដូចបានលើកឡើងខាងលើនេះជាបទពិសោធន៍អាក្រក់មួយ ដែលយើងត្រូវតែទប់ស្កាត់កុំឱ្យកើតមានជាថ្មីម្តងទៀត។

រហូតមកបច្ចុប្បន្ននេះ ការអប់រំសីលធម៌បានវិលត្រឡប់មករកសម័យដើមវិញហើយ ដោយយើងឃើញថា វត្តអារាមរីកដុះដាលយ៉ាងឆាប់រហ័ស យុវជនគ្រប់រូបអាចចូលបួសរៀនក្នុងសំណាក់ពុទ្ធសាសនាបានតាមចិត្ត។ ពិសេសជាងនេះទៅទៀត យើងឃើញថារដ្ឋាភិបាលបាលយកចិត្តទុកដាក់ អនុញ្ញាតឱ្យព្រះសង្ឃទៅអប់រំសីលធម៌ដល់កុមារ យុវជន ជាសិស្សានុសិស្សដល់ថ្នាក់រៀនតែម្តង។ ប៉ុន្តែការអប់រំតាមថ្នាក់ក្តីឬអប់រំតាមក្រុមក្តី ព្រះសង្ឃពុំមានលទ្ធភាពធ្វើបានទូទាំងប្រទេសនៅឡើយទេ។ ដោយហេតុថា យើងមានមូលដ្ឋានក្នុងការប្រតិបត្តិ ការអប់រំក្នុងវិស័យពុទ្ធសាសនាផង យើងជឿជាក់យុវជនជំនាន់ក្រោយក៏នឹងទទួលបានពុទ្ធិពីការអប់រំពុទ្ធសាសនាដូចសម័យមុនៗដែរតាមរយៈពុទ្ធិកសិក្សាដែលមានតាំងពីថ្នាក់បឋមរហូតដល់សាកលវិទ្យាល័យ។ ក្រសួងត្រូវតែពង្រីកការអប់រំនៅពុទ្ធិកសិក្សាឱ្យបានកាន់តែទូលំទូលាយដូចសាលាសាធារណៈដែរ។ ទន្ទឹមនឹងការពង្រីកនេះ តាំងពុទ្ធិកបឋមសិក្សារហូតដល់ថ្នាក់សាកលវិទ្យាល័យពុទ្ធិកក្រៅពីមុខវិជ្ជាស្នូល អ្នកជំនាញត្រូវបញ្ចូលមុខវិជ្ជាវិទ្យាសាស្ត្រឱ្យបានច្រើន និងជំរុញឱ្យសាមណសិស្សសាមណនិស្សិតឱ្យចេះស្រាវជ្រាវនិងមានបង្កើតជាព្រឹត្តិការណ៍ពានរង្វាន់ផ្សេងៗតាមដែលអាចធ្វើទៅបាន។

ជាមួយនឹងដំណើរការពង្រីកនិងពង្រឹងវិស័យអប់រំពុទ្ធសាសនានេះ ក្នុងនាមជាពុទ្ធសាសនិកម្នាក់សូមអំពាវនាវដល់សប្បុរសជនជាតិនិងអន្តរជាតិចូលរួមឱ្យបានកាន់តែច្រើននិងខ្លាំងក្លាបន្តទៀត។

## ឯកសារពិគ្រោះ


- គង់ សុឋានរិទ្ធ : ***ខ្មែរក្រហមមិនបំផ្លាញព្រះពុទ្ធសាសនាទេ*** វីអូអេខ្មែរ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១។
- ព្រំ ផល្លា : «ព្រះតេជគុណ ប៉ែន សេន ព្រះសង្ឃក្នុងរបបខ្មែរក្រហម» នៅក្នុង :***ទស្សនាវដ្តីស្វែងរកការពិត*** មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ៥៤ ខែមិថុនា ឆ្នាំ២០០៤ ទំព័រ១៨-១៩។
- វ៉ាន់ឌី កាអុន : ***ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាភាគ២***, ប៉ារីស, រោងពុម្ព [?] បោះពុម្ពលើកទី២, ឆ្នាំ២០០៨។
- ហុក សាវណ្ណ : ***តួនាទីរបស់ព្រះសង្ឃក្នុងសង្គមខ្មែរ*** ភ្នំពេញ, ឆ្នាំ២០០៨។
- ឡេង ម៉ាលី : ***សាសនានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ(ភាគ៧៤)*** វិទ្យុអាស៊ីសេរី (RFA) ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០០៨។
- អ៊ិត សារិន : ***ស្រណោះព្រលឹងខ្មែរ!*** ភ្នំពេញ, រោងពុម្ពពន្លឹងឯករាជ្យ បោះពុម្ពលើកទី១ ឆ្នាំ១៩៧៣។
- សម្ភាសន៍ លោក ***អ៊ូច ហឿន អតីតអ្នកបួសក្នុងឆ្នាំ១៩៧០*** នៅភូមិត្រពាំងឈើទាល ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ, ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៧។
- សម្ភាសន៍ លោក ***ជាល ហុន អតីតអ្នកបួសក្នុងឆ្នាំ១៩៧០*** នៅភូមិត្រពាំងឫស្សី ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ, ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៧។
- ***រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ*** ភ្នំពេញ, ឆ្នាំ១៩៧៦។
- www.d.dccam.org
- www.rfa.org/khmer
- www.rfi.org
- www.khmer.voanews.com
- https://www.eccc.gov.kh